**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីថ្លែងការណ៍
## របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

កាលពីយប់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ **ទណ្ឌិត សម រង្ស៊ី** បានផ្តល់កិច្ចសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី ដោយបានប្រើពាក្យអសុរោះធ្ងន់ៗ ប្រមាថមកលើព្រះកិត្តិនាម **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត របស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស និងជានិមិត្តរូបនៃឯកភាពជាតិ និងនិរន្តរភាពជាតិ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្កោលទោសយ៉ាងដាច់អហង្ការចំពោះ **ទណ្ឌិត សម រង្ស៊ី** ដែលបានប្រមាថយ៉ាងធ្ងន់ធ្ងរលើ អង្គព្រះមហាក្សត្រ ដែលជានិមិត្តរូបនៃប្រជាជាតិខ្មែរ និងត្រូវបានការពារ ដោយច្បាប់រដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងសូមធ្វើការអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ច ពិសេសស្ថាប័នអយ្យការ និងតុលាការគ្រប់ជាន់ថ្នាក់ ចាត់វិធានការតាមផ្លូវច្បាប់ចំពោះជនក្បត់ជាតិ និងបំផ្លិចបំផ្លាញជាតិរូបនេះ ចំពោះទង្វើយ៉ាងគឃ្លើន ដែលតែងតែប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតដល់ អង្គព្រះមហាក្សត្រ ដែលព្រះអង្គកំពុងគង់ប្រថាប់ បំពេញព្រះរាជតួនាទីដ៏ឧត្តុង្គឧត្តម ជូនជាតិមាតុភូមិ។

ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩